ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក

តុលាការកំពូល

សភាជំនុំជម្រះរដ្ឋប្បវេណី

សំណុំរឿងលេខ: ៣៣

ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨

សាលដីកា

លេខ : ១៦២

ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

ក្នុងបើកសវនាការជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៨ ដោយមានសមាសភាពដូចតទៅ :

១. ឯកឧត្តម ឌិត មុន្ទី ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២. លោក ប៉ែន ស៊ិន ជាចៅក្រម

៣. លោក ទេវល មួន ជាចៅក្រម

៤. លោក ស៊ុន ឌឹម ជាចៅក្រមរាយការណ៍

៥. លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី សាន នារី

តំណាងមហាអយ្យការ

លោក ជួន ស៊ិនទៀង

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៦៣៧ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២០៥ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ កៀម ហ៊ុង ហៅចាំង ធីយ៉ាង ភេទស្រី អាយុ៥២ ឆ្នាំ ជនជាតិវៀតណាម ទីលំនៅភូមិដើមពោធិ ឃុំកោះកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ។ ឪពុកឈ្មោះ ចែន ពី "ស" ម្តាយឈ្មោះ កៀម ជី "ស" ប្តីឈ្មោះដាំង យ៉ាំងយ៉ាក មានកូនបីនាក់ ។

និងចុងចម្លើយឈ្មោះ ស្រ៊ិន មាលីស ហៅនាងលីន អាយុ៥៥ឆ្នាំជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅភូមិរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល ។ ឪពុកឈ្មោះទេព្យា តារ "ស" ម្តាយឈ្មោះ ទេព្វាង សុខទៀង "រ" មានកូនបីនាក់ ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារប្រាក់សំណង ។

ក្នុងដីកាបណ្តឹងសាទុក្ខលេខ ៤៨១ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ របស់ឈ្មោះ កៀម ហ៊ុង ហៅចាំង ធីយ៉ាង ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចទាំងមូលរបស់សាលាឧទ្ធរណ៍ ។

ក្នុងដីកាសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ _

របស់តុលាការកំពូល ។

តាមបណ្ដឹង ចុះថ្ងៃទី១៣-០២-៨៧ របស់ឈ្មោះកេង ហ៊ុនហៅចាំង ពីឈាំងថា នៅថ្ងៃទី-៣០.៧.៨៦ ឈ្មោះជាតឹម ប្អូននិងខ្លួនបានធ្វើកិច្ចសន្យាដើម្បីចិញ្ចឹមពូជត្រីស្នោរ ។ជាតឹម ប្អូនបានទិញកូនត្រីចំនួន៣តោន អោយខ្លួនចិញ្ចឹមអោយបាន៨ខែ៩តោន ថា អោយថ្លៃឈ្នួលចិញ្ចឹម១០តម្លឹងមាស តែបើបាន៩តោនទេ ខ្លួនត្រូវចេញសងទៅឈ្មោះនេះអោយបានគ្រប់ចំនួន៩តោន ។ក្រោយពីធ្វើកិច្ចសន្យាបានប្រហែល០៣ខែ-ឈ្មោះជា តឹមប្អូនបានស្លាប់ស្ទះដល់ថ្ងៃកំណត់លក់ត្រីប្រពន្ធរបស់ជា តឹមប្អូន ឈ្មោះស្រ៊ុន ម៉ាលីសបានទៅប្ដឹងនៅអាជ្ញាធរឃុំ និងស្រុកចុះរឹបអូសយកត្រីទៅលក់ ហើយពុំព្រមចេញឈ្នួលចិញ្ចឹមចំនួន១០តម្លឹងមាសមកខ្លួនទើយ ។

បានឃើញសាលក្រមលេខ៣៤ "វ" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៨៧ របស់តុលាការខេត្តកណ្ដាល ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១.ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ១៣.២.៨៧ របស់នាងចាំង ពីឈាំង "ដើមចោទ" មានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២.ទទួលពាក្យបណ្ដឹងចុះថ្ងៃទី៩.២.៨៧ របស់នាងស្រ៊ុន ម៉ាលីសហៅពឹង "ចុងចម្លើយ" មានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

៣.បង្គាប់អោយនាងចាំង ពីឈាំង "ដើមចោទ" សងប្រាក់ទៅអោយនាងស្រ៊ុន ម៉ាលីសចុងចម្លើយចំនួន១.៥០០ដុល្លាអាមេរិកមាសពេជ និងប្រាក់រៀលចំនួន៣២.២៣២.០០០រៀល" (សាមសិបពីរលានពីរសែនបី-ម៉ឺនពីរពាន់រៀល) ។សុំលើសពីនោះលើកចោល ។

បើគ្មានប្រាក់សងទេត្រូវរឹបអូសទ្រព្យសម្បត្តិលក់ទៀតទៀង បើគ្មានទ្រព្យសម្បត្តិត្រូវដាក់គុកបង្ខំលើរូបកាយចំនួន៨ខែ តាមបញ្ញត្តិមាត្រា១៣៣នៃច្បាប់ស្ដីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ៥១ក្រ ចុះថ្ងៃទី២.៥.៨២ ។

៤.បង្គាប់អោយនាងស្រ៊ុន ម៉ាលីស "ចុងចម្លើយ" ប្រគល់ទ្រព្យសម្បត្តិទៅអោយដើមចោទ-រួមមាន :

១.ម៉ាស៊ីនយ៉ាន់ម៉ា៥សេស១គ្រឿងពណ៌ក្រហម

២.មេទឹកត្រី ២ ខាប់

៣.ស្បៃជរ ០១ ដុំ

៤.ចានដែកឯកត្រកដរ១និងខោអាវមួយចំនួន សុំលើសពីនេះលើកចោល ។

៥.បង្គាប់អោយដើមចោទបង់ប្រាក់ប្រដាប់ក្ដីសរុប៧.០០០រៀល គឺពន្ធចុះបញ្ជីក្ដីនិងពន្ធញ្ញើ ១.៨០០រៀល រង្វាន់ក្រឡាបញ្ជី២០០រៀល ពន្ធតើបសួរ៥.០០០រៀល ។ ប្រាក់នេះបានកាត់យកពីប្រាក់ប្រដាប់ក្ដីដែលដើមចោទតាមមាត្រា ៧.១០.១៦ នៃច្បាប់ស្ដីពីការបង់ប្រាក់ប្រដាប់ក្ដី ដែលប្រកាស-អោយប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី៧.៣.៨៣ ។

សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគី ។ គូភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍រយៈពេល២ខែចាប់គិតពីពេលនេះតទៅ ។

បានឃើញពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៣_៨_៩៧ របស់ភាគីដើមចោទ ប្ដឹងមិនសុខចិត្តលើសេចក្ដីសំរេច ទាំងមូល ។

បានឃើញសាលដីកាលេខ ៦៣៧ ចុះថ្ងៃទី២៧_១០_៩៧ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១. ទទួលបណ្ដឹងឧទ្ធរណ៍របស់នាងចាំង ពីយ៉ារ៉ុង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២. បដិសេធចំណុច៣ នៃសាលក្រមរដ្ឋប្បវេណីលេខ ៣៤ "ក" ចុះថ្ងៃទី២៧.៣.៩៧ របស់តុលាការខេត្តកណ្ដាលចោលជាអាសារបង់ ហើយសំរេចអោយបានត្រឹមត្រូវឡើងវិញ ចំណុចក្រៅពីនេះរក្សាទុកដដែល ។

៣. បង្គាប់អោយនាងចាំង ពីយ៉ារ៉ុង ព្រមទាំងប្ដីឈ្មោះដាំង យ៉ារ៉ុងម៉ាត សងខាងសចំនួន៤៨២ ពី "បួនតម្លឹងក្រវិលពីរពិនពីរ" ដែលជាចំនួនប្រាក់សល់ពីការគិតប្រាក់ការ និងប្រាក់ ៣ដីម្ចាស់ព្រមទាំង ១.៥០០ដុល្លា "មួយពាន់ប្រាំរយដុល្លា" ដែលជាប្រាក់ដើមពាក់អោយទៅនាងស្រ៊ិន ម៉ាលីសវិញ ។

បើគ្មានប្រាក់សងទេ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង ហើយបើគ្មានទ្រព្យសម្បត្តិ ត្រូវដាក់គុកជំនួសរូបកាយចំនួន៨ខែ តាមបញ្ញត្តិមាត្រា ១៣៣នៃច្បាប់ស្ដីពីវិធីអនុវត្តសាលក្រម ។

៤. រឹបអូសប្រាក់ប្រដាប់ក្ដីទៅជាន់សាលាឧទ្ធរណ៍ គិតពន្ធបណ្ដឹងនិងពន្ធចុះបញ្ជីក្ដីចំនួន២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាត់ពីប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀលនិងចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១.៣០០រៀល ដែលនាងចាំងពីយ៉ារ៉ុងបានបង់រួចហើយ ។

កាលបើសាលដីកានេះចូលជាស្ថាពរ បង្គាប់អោយនាង ចាំង ពីយ៉ារ៉ុងបង់ពន្ធសមាព្រហ្មភាគ លើចំនួនប្រាក់ ៤.៨២២ ពី ។ ប្រាក់ពន្ធនេះ៨០ភាគរយ ត្រូវបានជាប្រយោជន៍ ថវិកាជាតិ និង ២០_ភាគរយត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៥. សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈនាពេលសវនាការចំពោះគូក្ដី សំរេចបើកផ្លូវប្ដឹងសាទុក្ខរយៈពេលពីរខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញពាក្យបណ្ដឹងសាទុក្ខលេខ ៤៨១ ចុះថ្ងៃទី ១៥_១២_៩៧ របស់អ្នកស្រីកៀម ស៊ុង ធ្វើឡើង ក្នុងកំណត់ច្បាប់ ។

បានឃើញលិខិតបង្គាប់អោយធ្វើសារណា ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់ឈ្មោះ_ កៀម ស៊ុង ជាម្ចាស់បណ្ដឹងសាទុក្ខ តែមិនបានធ្វើសារណាទេ ។

បានស្ដាប់ចម្លើយរបស់អ្នកស្រី ស្រ៊ិន ម៉ាលីស ជាចុងចម្លើយសាទុក្ខបានឆ្លើយក្នុងពេលសវនាការថា: ខ្លួនសុំឲ្យតុលាការជួយរកយុត្តិធម៌អោយខ្លួនផង និងសុំឲ្យជួយរឹបអូសទ្រព្យសម្បត្តិប្រសិនបើមិនមានប្រាក់គ្រប់ចំនួន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖

ក្រោយពីបានពិនិត្យលើសាលដីកាឧទ្ធរណ៍លេខ ៦៣៧ ចុះថ្ងៃទី២៧.១០.៨៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងលើនីតិច្បាប់ហើយ ។ គប្បីបញ្ជូនសំណុំរឿងឧទ្ធរណ៍លេខ ៣៣ – ចុះថ្ងៃទី០៣-០២-៨៨ ទៅសាលាឧទ្ធរណ៍វិញ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ ទទួលពិចារណាតាមច្បាប់តទៅ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់អ្នកស្រីស៊ើន ម៉ាលីន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

## តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤៨៩ ចុះថ្ងៃទី១៥.១២.៨៧ របស់អ្នកស្រីកៀម ម៉ឺនត្រឹមត្រូវក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដើមចោទនិងចុងចម្លើយពិតជាបានធ្វើកិច្ចសន្យាជាមួយគ្នា ថវិកាមត្រីឆ្តោទម្ងន់ ៥តោន អោយបានទៀងទាត់ទម្ងន់១៥តោនក្នុងរយៈពេលពីរខែ ដែលមានតម្លៃថវិកាម ១០ តម្លឹងមាស ក្នុងទម្ងន់ត្រីចំនួន ៣ តោនរួចហើយជា ១៦តម្លឹង៦ជី៦ហ៊ុននិង៦លីប្រាកដហើយ ។

យល់ឃើញថា កិច្ចសន្យាបានកំណត់យ៉ាងច្បាស់ថាបើភាគីទទួលថវិកាមក បានគ្រប់ចំនួនអោយម្ចាស់ត្រី ត្រូវចេញត្រីផ្តល់អោយគ្រប់ចំនួនដូចចែងខាងលើអោយទៅអ្នកថវិកាមវិញ ។ ក្នុងករណីអ្នកទទួលថវិកាមក ពុំបានគ្រប់ចំនួនតាមកិច្ចសន្យាអោយម្ចាស់ត្រីទេ អ្នកសុំយកថវិកាមត្រីត្រូវសងត្រីអោយគ្រប់ចំនួន១៥តោនអោយទៅម្ចាស់ត្រីវិញ ។

យល់ឃើញថា ការដែលសាលាឧទ្ធរណ៍យល់ថាភាគីសុំយកថវិកាមត្រីត្រូវសងទៅភាគីម្ចាស់ត្រីចំនួន១០.៣៥៥ គីឡូក្រាមទៀតនោះជាការភាន់ច្រឡំ ពីព្រោះថាការចាប់ត្រីថវិកាមលក់ដែលធ្វើឡើងដោយគណៈសម្ម ការចំរុះ ហើយដោយពុំមានការចូលរួមពីភាគីថវិកាមត្រីនិងពុំមានចំណាត់ការពីតុលាការផងនោះពុំអាចយកជាការបានទេ ។

យល់ឃើញថា អ្នកស្រី កៀម ម៉ឺនចៅចាំង ពីព្រោះបានទទួលលិខិតអោយធ្វើសារណាការពារក្តីរបស់ខ្លួនហើយប៉ុន្តែពុំបានធ្វើសារណាផ្ញើមកតុលាការកំពូលទេ ហើយក៏ពុំបានមកចូលរួមសវនាការនេះដែរ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខអ្នកស្រីប៉ុន្តែចាត់ទុកជាចំពោះមុខ ។

យល់ឃើញថា សាលដីកាឧទ្ធរណ៍លេខ៦៣៧ ចុះថ្ងៃទី២៧.១០.៨៧ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងនីតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដី ចំពោះមុខអ្នកស្រីស្រ៊ិន ម៉ាលីស កំបាំងមុខអ្នកស្រីកៀម ឃីង
ប៉ុន្តែចាត់ទុកជាចំពោះមុខ

១.ទទួលបណ្ដឹងសាទុក្ខលេខ៤៨១ ចុះថ្ងៃទី ១៥.១២.៨៧ របស់អ្នកស្រីកៀម ឃីងទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២. ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៦៣៧ ចុះថ្ងៃទី២៧.១០.៨៧ របស់សាលាឧទ្ធរណ៍ - ទាំងមូល ។

៣. បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី០៣.០២.៨៨ របស់តុលាការកំពូលទៅសាលា - ឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤. រឹបអូសប្រាក់ប្រដាប់ក្ដីដែលអ្នកស្រីស្រ៊ិន ម៉ាលីសបានដំកល់ទុកនៅតុលាការកំពូលចំនួន១៨.០០០៛០០ គឺ :

- ពន្ធចុះបញ្ជីក្ដី និងពន្ធបណ្ដឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់
- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៨.០០០រៀល

៥.សាលដីកានេះប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៨៨ ។